ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 12 / 2015
ម៉ោង (Time/Heure): 11:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**
**សាធារណៈ**

# សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

# ថ្ងៃ ច័ន្ទ ទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥

# សវនាការលើភ័ស្តុតាង - ថ្ងៃ ៣៤៥

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Matthew J. McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, លោក Matthew J. McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង លាង, លោក Joseph Andrew BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក ឡោ ជុនធី, លោក ហុង គឹមសួន, លោកស្រី ជេត វណ្ណលី, លោកស្រី ស៊ីន សុវ៉ន |
| សាក្សី/ដើមបណ្តឹង៖ សៅ សាក់ (2-TCW-886), ជឿង យ៉ាំងចែត (2-TCCP-241) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, កញ្ញា សំ មករា, លោក ឡូញ ង៉ែត, លោក នូ មនោរ័ត្ន, កញ្ញា ណី សុមេត្តា, កញ្ញា Elena FAVARO VIANA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៩ | បញ្ចប់ម៉ោង៖ ១៦.០២ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣២ | បញ្ចប់ម៉ោង៖ ១៣.៣៣ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១០ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៩ | ០៩.១១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.១១ | ០៩.១៣ |
| ការតាំងសំណួរទៅកាន់សាក្សី សៅ សាក់ (2-TCW-886) | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.១៣<br>០៩.៣២<br>០៩.៤៨<br>១០.៣១ | ០៩.៣២<br>០៩.៤៧<br>១០.១០<br>១០.៤៣ |
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត (2-TCCP-241) | អង្គជំនុំជម្រះ<br>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១០.៤៣<br>១០.៥១<br>១៤.៣៣<br>១៥.២១ | ១០.៥១<br>១៤.៣៣<br>១៥.២៤<br>១៥.២៤ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្ដី នួន ជា | ១៥.២៤ | ១៦.០១ |
| សេចក្ដីសម្រេចផ្ទាល់មាត់អំពីសាក្សីថ្មី ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ជនជាតិ វៀតណាម | អង្គជំនុំជម្រះ | ១៣.៣៣ | ១៣.៣៩ |

\

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅកាន់សាក្សី សៅ សាក់ (2-TCW-886)**

សហព្រះរាជអាជ្ញា សហមេធាវីនាំមុខ មេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរទៅកាន់សាក្សី សៅ សាក់ (2-TCW-886)។

**ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត (2-TCCP241)**

អង្គជំនុំជម្រះ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី នួន ជា បានតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត (2-TCCP-241) ។

**សេចក្ដីសម្រេចផ្ទាល់មាត់អំពីសាក្សីថ្មី ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ជនជាតិវៀតណាម**

អង្គជំនុំចម្រះសម្រេចយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលបានស្នើសុំកោះហៅសាក្សីថ្មីបន្ថែមសម្រាប់អង្គហេតុការប្រព្រឹត្តិលើក្រុមគោលដៅជាក់លាក់ ជនជាតិវៀតណាម (សូមមើលឯកសារ E319/36 កថាខណ្ឌ ១១, ១២ និងប្រតិចារិកសវនាការថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២-១៣) ហើយបានដាក់របាយការណ៍ឲ្យសាក្សីថ្មីនោះគឺ សាក្សី 2-TCW-1000។ អង្គជំនុំជម្រះ

កំបានទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី 2-TCW-1000 ដែលទើបតែនឹងត្រូវបានដាក់បង្ហាញគឺ ឯកសារ E319/23.3.44, E319/23.3.45, E319/23.3.46, E319/23.3.47 និង E319/23.3.48។

<u>**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភ័ស្តុតាង**</u>

**Reclassified**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/2589 | | 00224668-00224670; 00224671-00224673; 00623345-00623349 | "A Cambodian-Vietnamese Couple Under the Khmer Rouge", DC-Cam Searching for the Truth, Special English Edition, No 65, May 2005. | P | 00224670 | 00224673 | 00623348 |
| E3/5325 | | 00451599-00451663; 00824132; 00824205; 00869244-00869301 | Interview with complainant KHON Mon | P | 00451643; 00451644 | 00824184; 00824185 | 00869284; 00869285 |
| E3/7783 | | 00238896-00238899; 00242214-00242217; 00281805-00281808 | Written Record of Interview of YIM Muoy | P | 00238898 | 00242216 | 00281807 |
| E3/7780 | | 00233294-00233297; 00235510-00235513; 00250599-00250602 | Written Record of Interview of SAO Sak | P | 00233296; | 00235511; 00235512 | 00250600; 00250601 |
| E3/5631 | | 00897513-00897515; 00678292-00678293; 00898371-00898374 | Supplementary statement of CHOEUNG Yaing Chaet | P | 00897513; 00897515 | 00678292; 00678293 | 00898372; 00898372 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/20 | | 00231987-00232710; 00237694-00238316; 00638281-00638721 | Book by Elizabeth Becker entitled "When the War was Over" | P | 00232165-00232166 | 00237829-00237830 | 00638396-00638397 |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១៣)
- សេចក្ដីសម្រេចផ្ទាល់មាត់សម្រេចកោះហៅសាក្សីថ្មីតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះការប្រព្រឹត្តលើក្រុមគោលដៅជាក់លាក់ ជនជាតិវៀតណាម ដោយដាក់រហស្សនាម 2-TCW-1000 និងសម្រេចទទួលយកជាភស្តុតាងនូវឯកសារ E319/23.3.44, E319/23.3.45, E319/23.3.46, E319/23.3.47 និង E319/23.3.48 ។ (១៣.៣៩)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៥។ (១៦.០២)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីទបរ៉ា Matthew J. McCARTHY